# ការសំភាសន៍លើកទី១របស់អ្នកមីង ទូច ស្រី

កៈ អ្នកដែលសំភាសន៍ឈ្មោះញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ ទូច ស្រី

## ការសង្ខេបរបស់អ្នកមីង ទូច ស្រី

អ្នកមីងទូច ស្រី
គាត់បានកើតនៅក្នុងក្រុមគ្រួសារដែលជាអ្នកធ្វើស្រែចំការហើយម្តាយលក់បន្លែខ្លះហើយឪពុកជាជាងសំនង់
អ្នកមីងមានបងប្អូនតែ២នាក់គឺគាត់នឹងបងប្រុសតែបងប្រុសបានស្លាប់ទៅហើយ។
ជីវិតអ្នកមីងពិបាកហើយ រស់នៅសព្វថ្ងៃគឺមិនស្រួលទេ
គាត់គ្មានផ្ទះសម្បែងហើយត្រូវជួលផ្ទះគេរស់នៅ
ព្រោះដោយសារជំងឺគាត់ត្រូវលក់ផ្ទះដើម្បីមើលខ្លួនហើយស្វាមីនឹងកូនក៏ឈឺគឺសុទ្ធតែជាជំងឺដែរពិបាក។ ហើយស្វាមីមិនរកស៊ីអ្វីដោយសារជំងឺ ហើយគាត់ដើររើសអេតចាយដើម្បីចិញ្ចឹមជីវិតហើយកូនប្រុសម្នាក់ឈឺហ្នឹងគឺស្លាប់មួយចំហៀងខ្លួនហើយដើរសុំទានគេដើម្បីយកលុយមកទិញថ្នាំហើយទិញម្ហូបអាហារ។ គាត់រស់នៅដោយលំបាកសំរាប់សព្វថ្ងៃហ្នឹង។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីង នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវិតរបស់អ្នកមីងនៅក្នុងថ្ងៃនេះ
ហើយថ្ងៃដែលពួកយើងសំភាសន៍គឺនៅក្នុងថ្ងៃទី០៥ ខែកុម្ភៈ ថ្ងៃ០៦ខែកុម្ភៈ ឆ្នាំ២០១៨
ការសំភា សន៍នេះមានទីតាំងស្ថិតនៅក្នុងភូមិព្រែកហូរខាងលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្ត កណ្តាល ប្រទេសកម្ពុជា ហើយដែលមាននាងខ្ញុំឈ្មោះ ញ៉ែម សុគន្ធា
ជាអ្នកសំភាសន៍អ្នកមីងនៅក្នុងថ្ងៃនេះផងដែរ។
អ៊ីចឹងញ៉ុមនឹងសួរអំពីជីវិតរបស់អ្នកមីងថាតើគាត់បានឆ្លងកាត់អីគេខ្លះនៅក្នុងជីវិតហ្នឹង!!
អ៊ីចឹងអ្នកមីងសូមប្រាប់ឈ្មោះពេញរបស់អ្នកមីងហា!!

ខៈ ញ៉ុម?

ក៖ ចាំ!!

ខ៖ឈ្មោះញុំមម៉ងហេ?

ក៖ចាំ!!

ខ៖ ឈ្មោះញុំម ទូច ស្រី។

ក៖ ចាំអីចឹងអ្នកមីងមានឈ្មោះអីផ្សេងក្រៅពីទូច ស្រីហ្នឹងទៀតទេ?

ខ៖ អត់មានផងមានតែឈ្មោះមួយហ្នឹង !! យកឈ្មោះឪញុំមហ្នឹង(ត្រកូល)។

ក៖ អីចឹងនៅក្នុងបញ្ជីជាតិឈ្មោះ ម៉ែន ស្រី ឬក៏ ទូច ស្រី?

ខ៖ ទូច ស្រីតែម្តង។

ក៖ ទូច ស្រី!!

ខ៖ ចាំ!!

ក៖ ហ្នឹងត្រូវហើយអីចឹង។ពេលនៅពីក្មេងមានអ្នកណាគេហៅអ្នកមីងផ្សេងពីហ្នឹងទេ?

ខ៖ អត់មានអ្នកណាគេហៅផងហ្នឹងហេ!!

ក៖ ហៅតែឈ្មោះមួយហ្នឹងទេហេ?

ខ៖ ចាំ!!ហេនៅពីក្មេងហៅតែឈ្មោះហ្នឹង!!

ក៖ ហៅតែស្រីៗៗអីចឹងទៅមីងណេះ?

ខ៖ ចាំ ចាំ!!

ក៖ មីងសព្វថ្ងៃអាយុប៉ុន្មានហើយ?

ខ៖ ឆ្នាំមមែអាយុប៉ុន្មាន?

(ស្វាមី)៖ ៥៣។

ខ៖ ៥៣។

ក៖ ៥៣ឆ្នាំហើយ!!

ខ៖ ចាំ!!

ក៖ ៥៣ឆ្នាំឆ្នាំមមែ?

ខ៖ចាំ!!

ក៖សត្វក្តាន់។

ខ៖ ពពែ។

ក៖ សត្វក្តាន់ អីយ៉ាស់ច្រឡំសត្វក្តាន់អត់មានផងឆ្នាំអត់មានក្តាន់ផង!!

ខ៖ មានតែពពែ។

ក៖ ពិបាកណាស់ញ៉ុម ឆ្នាំក្តាន់!!

ខ៖ ឆ្នាំមមែ ពពែ!!

ក៖ អ្នកមីង អ៊ីចឹងអ្នកមីងចាំឆ្នាំបារាំងរបស់ខ្លួនឯងទេ?

ខ៖ អត់ចាំផងញ៉ុមចាំតែឆ្នាំខ្មែរហ្នឹង!!

ក៖ ថ្ងៃខែឆ្នាំខ្លួនឯងកើតអត់ចាំដែរ?

ខ៖ អត់។

(ស្វាមី)៖ នៅក្នុងបញ្ជីជាតិទាំងអស់។

ក៖ហ្ហ៎!!!

(ស្វាមី)៖ហើយទទួលបញ្ជីជាតិហ្នឹងវាជាប់សោរនៅក្នុងហិបទៅ។

កៈ ចាំអញ្ចឹងអ្នកមីង សំរាប់អ្នកមីងកើតមុនសង្គ្រាមមែនទេ?ក្នុងពេលហ្នឹង ញ៉ុមគិតថាយូរដែរហើយមីងណោះ?

ខៈ ហេពេលញ៉ុមកើតចង់និយាយថាសង្គ្រាមពេលអាពតហ្នឹងហោ?

កៈចាំ!!មីងអាយុប៉ុន្មានហើយពេលសង្គ្រាមប៉ុល ពតហ្នឹង?

ខៈ ញ៉ុមនៅទូចៗ។

កៈ ទូចទេហោ?

ខៈចាំ!!

កៈ ហ្នឹងហើយ។

ខៈ នៅស៊ីបាយ បបរ។

កៈ អញ្ចឹងអ្នកមីងប្រហែលជាកើតនៅឆ្នាំ១៩៦០ជាងហ្នឹង អ៊ីចឹងបើឆ្នាំ២០១៨មីងអាយុ៥៣ឆ្នាំ អាណាគេចង់ដឹងអីវ៉ាន់គេដកមើលតាមហ្នឹងទៅគេឃើញហើយ!!ហ្នឹងហើយ អញ្ចឹងមីងចាំថាខ្លួនឯងកើតនៅក្នុងភូមិណាទេ?

ខៈ នេះខេត្តទន្លេបាទីហ្នឹង!!ទន្លេបាទីយើងនេះ!!

(ស្វាមី)៖ ស្រុកទន្លេបាទី។

កៈ ស្រុកទន្លេបាទីហោ?

ខៈ ហ្នឹងស្រុកទន្លេបាទីហ្នឹង។

(ស្វាមី)៖ ខេត្តតាកែវ។

ខៈ កំពង់កោរ។

កៈ ហ្ហ៎នៅកំពង់កោរហ្នឹងហី?

ខៈ ហ្នឹងហើយ ទន្លេបាទីកំពង់កោរហ្នឹង។

កៈ ចាំ!!នៅខេត្តតាកែវហ្នឹង?

ខៈចាំ!!

កៈ មីងបងប្អូនដូនតាមកគឺនៅហ្នឹងរហូតម៉ងហេ?

ខៈ នៅហ្នឹងរហូតម៉ង អត់មានទៅណានៅហ្នឹងរហូតម៉ង!!

កៈ មីងភាគច្រើនអ្នកនៅស្រុកភូមិហ្នឹងភាគច្រើនគេរកស៊ីមុខអីគេដែរ?

ខៈ នៅហ្នឹងហេ?

កៈចាំ!!

ខៈដឹងគេរកស៊ីអីបើញ៉ុមគេរ៉ៃបែកពីភ្នំពេញមក!!

(ស្វាមី)ៈ ធ្វើស្រែ។

កៈ ពេលមុនហ្នឹងហាំ??

ខៈ ហ្នឹងហើយធ្វើស្រែ។

កៈ ហើយមានមុខរបរអីទៀតទេ?

ខៈ អត់មានអីទេ មានតែធ្វើស្រែហ្នឹង។

កៈ តែប៉ុណ្ណឹងទេហេ?

ខៈចាំៗ!!

កៈ ហើយនៅហ្នឹងសំបូរត្នោតអីអត់មីង?

ខៈ សំបូរត្នោតហេ!!សំបូរដែរ សំបូរណាស់។

កៈ តែគ្រួសារអ្នកមីងមានដែលធ្វើត្នោត ស្ករត្នោតអីវ៉ាន់អី?

ខៈ អត់!!

ក៖ កន្ទេលស្លឹកត្នោតអីវ៉ាន់ហាំ?

ខ៖ អត់មានផង។

ក៖ អ៊ីចឹងសំរាប់គ្រួសារអ្នកមីង ដើម្បីរកស៊ីចិញ្ចឹមជីវិតអ្នកមីងធ្វើអីគេទៅអញ្ចឹង?

ខ៖ តាំងពីហ្នឹង!!

(ស្វាមី)៖ ធ្វើស្រែ លក់ដូរ។

ខ៖ ធ្វើស្រែលក់ដូរបន្លែ លក់ដូរអីហ្នឹង។

ក៖ ហ្ញុំអ៊ីចឹងមានដាំបន្លែដែរពេលហ្នឹងហី?

ខ៖ អត់ទេតែទទួលគេលក់។

ក៖ ហ្ញុំអ្នកណាធ្វើមួយហ្នឹងវិញអ្នកមីងឬក៏ម្ដាយ?

ខ៖ ទទួលគេហ្នឹងម៉ង!!

ក៖ តែអ្នកមីងលក់ ឬក៏ម្ដាយជាអ្នកលក់?

(ស្វាមី)៖ ម្ដាយលក់កាលពីដើម។

ក៖ ម្ដាយអ្នកលក់ទេហេ?

ខ៖ ចាំ!!

ក៖ចាំអ៊ីចឹងអ្នកមីងសំរាប់អ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ញុំមមានឯណា។

(ស្វាមី)៖ ឥឡូវគ្នាកំព្រាបងប្អូនហើយ។

ខ៖មានតែម្នាក់ឯងហ្នឹង។

(ស្វាមី)៖ បងប្អូនស្លាប់អស់ហើយហ្នឹង។

កៈ ហ្ហ៎!!តែបងប្អូនអត់ទាន់នេះពេលនេះហាំបងប្អូនអត់ទាន់ស្លាប់មានប៉ុន្មាននាក់?

ខៈ អត់ម៉ង!!

(ស្វាមី)៖ មាន២នាក់ ចេះតែមានហើយ។

(កូន)៖ ពេលមិនទាន់ស្លាប់ម៉ែឯងមានបងប្អូនប៉ុន្មាននាក់?

(ស្វាមី)៖ កាលមិនទាន់ស្លាប់ខ្មោចបងខនមិនទាន់ស្លាប់ហ្នឹងមិននៅ២នាក់បងប្អូន។

ខៈ មាន២នាក់។

កៈ អញ្ជឹងមានតែ២នាក់បងប្អូនហេ?

ខៈ ចាំ!!

កៈ ឈ្មោះអីគេបង?

ខៈ ឈ្មោះខន។

កៈ ខន?

ខៈ ហ្នឹងហើយ យិន ខន។

(ស្វាមី)៖ យិន សុខន។

កៈ អញ្ជឹងឈ្មោះ ត្រកូលមីងត្រកូលទូច?

ខៈចាំ!!

កៈតែម៉េចដាក់ឈ្មោះផ្សេងគ្នាវិញមីង?ដាក់ឈ្មោះត្រកូលផ្សេងគ្នាវិញ?

(ស្វាមី)៖មួយយកត្រកូលម្ដាយ។

(កូន)៖ មួយយកត្រកូលឪពុក។

កៈ ទៅអីចឹងទៅឡើងវល់។

(ស្វាមី)៖ ឯណោះត្រកូលខាងឪពុក។

ក៖ ចាំហ្នឹងហើយ អ៊ីចឹងមីងសំរាប់បង បងស្រីឬមួយក៏បងប្រុស?

ខ៖ ប្រុស។

ក៖ គាត់ជាបងហើយមីងជាប្អូនគេអ៊ីចឹងហេ?

ខ៖ បងបង្កើតម៉ង។

ក៖ ហ្វាំឈ្មោះយិន អីគេមិញ?

(ស្វាមី)៖ យិន សុខន។

ខ៖ យិន សុខន។

ក៖ ចាំគាត់ស្លាប់នៅពេលណាវិញមីង?

ខ៖ ស្លាប់ពេលណាជំនាន់!!

(ស្វាមី)៖ ស្លាប់នៅក្នុងឆ្នាំ៨៣(១៩៨៣)។

ក៖ ចាំ ១៩៨៣គាត់ស្លាប់ហ្នឹងមីងហេ?

ខ៖ ចាំ!!

ក៖ បងប្រុស។

ខ៖ បងប្រុស !!

ក៖ មូលហេតុអីដែលបងប្រុសអ្នកមីងគាត់ស្លាប់ដែរ?

ខ៖ សង្គ្រាម។

ក៖ ពេលហ្នឹងលែងមានសង្គ្រាម។

(ស្វាមី)៖ ពេលហ្នឹងសង្គ្រាមចប់ហើយ។

កៈ មកពីណាចប់ហើយហី??

ខៈ គាត់នៅតែធ្វើ!!

(ស្វាមី)៖ ប៉ុន្តែដោយសារគាត់ស្លាប់នេះដោយសារគាត់កើតពិស។

កៈ ហ្អ៎អីចឹងដោយសារជំងឺមីងហោ?

ខៈ ចាំ!!

កៈ ប៉ុន្តែលោកពូចាំជាង?

ខៈ ញ៉ុមមិនសូវចាំទេ។

(ស្វាមី)៖ ញ៉ុមមិនចាំម៉េចបើញ៉ុមបានគ្នាតាំងពី១៧ ១៨ ឆ្នាំណោះ!!

កៈ ហ្អ៎ហ្នឹងហើយ។

(ស្វាមី)៖ រហូតមក មានផ្លាស់ប្តូរទៅឯណា!!

កៈ អីចឹងមីងសំរាប់មីងតើមីងចាំអីគេខ្លះពីបង តើអ្នកមីងបានលេងអីគេខ្លះ
គាត់មានចរិកគាត់ម៉េចដែរ?

ខៈ មានណាជំនើរបងញ៉ុមគ្រុនចាញ់ហ្នឹងហី!!

កៈ ដឹងហើយតែចរិករបស់គាត់ជាមនុស្សយ៉ាងម៉េចដែរ មិនមែនសួរពីជំងឺទេ!!

(ស្វាមី)៖ មានអីស្រលាញ់បងប្អូនសឹងអីហ្នឹង។

កៈ អត្តចរិករបស់បងប្រុសមីងហាំ!!

(កូន)៖ គាត់ស្លូតបូតឬក៏អត់?

ខៈ គាត់ស្លូតបូតតើ!!គាត់មានកាចអីគាត់!!!ស្លូតបូតហ្នឹង!

កៈ ភាគច្រើនគាត់លេងអីគេជាមួយមីងដែរ? ពេលនៅពីតូចអីចឹងហាំ!!

ខ៖ ចេះតែស្រលាញ់ប្រហែងជាមួយបងប្អូនដែរ ចុះមានតែ២នាក់បងប្អូនដែរហ្នឹង មានបងប្អូនឯណាមានតែ២នាក់ហ្នឹង!!

ក៖ គាត់បងរបស់មីងប៉ុន្មានឆ្នាំ?

ខ៖ មិនដឹងប៉ុន្មានទេ។

(ស្វាមី)៖ខ្ទង់ប្រហែលជា៩ ១០ឆ្នាំ!!

ក៖ អ៊ីចឹងបងប្រុសអ្នកមីងគាត់កើតនៅកំពង់កោរហ្នឹងដែរហោ?

ខ៖ ជាមួយគ្នា!!

ក៖ ពីរមុនគាត់ស្លាប់ហ្នឹងគាត់ការហើយឬនៅមីង?

ខ៖ គាត់មានកូន៤នាក់ហើយកូនហ្នំ!!

(ស្វាមី)៖ តែកូនហ្នឹងឥឡូវមានប្ដីប្រពន្ធអស់ហើយ។

ក៖ ចាំ ហើយអ៊ីចឹងប្រពន្ធគាត់ម៉េចដែរឥឡូវ?

ខ៖ ប្រពន្ធនោះហ្នំ ប្រពន្ធគាត់នៅស្រុកកអីគេ!!

(ស្វាមី)៖ នៅខាងព្រះវិហារ។

ខ៖នៅខាងព្រះវិហារ!!

ក៖ នៅខាងព្រះវិហារវិញអ៊ីចឹងហោ?

ខ៖ ចាំ!!

ក៖ សុទ្ធតែចំណាស់ៗអស់ហើយមីងណោះ?

ខ៖ ចាំ!!

ក៖ ចាំ!!អីចឹងមីងចូលដល់ម្ដាយរបស់មីងសិន ម្ដាយរបស់អ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ ម៉ែន ផុស។

ក៖ ម៉ែន ផុស!!

ខ៖ ចាំ!!

ក៖ តែអើរដល់ពេលយាយផូ ម៉េចដាក់យិន ផូវិញ?ក្រែងឃើញបងប្អូនគាត់បង្កើតសោះ?

(ស្វាមី)៖ ត្រកូលពូជខាងឪពុក!!

ក៖ ហ្ហ៎អ៊ីចឹងយកឈ្មោះផ្សេងគ្នាទាំងអស់?ខ

ខ៖ ហ្នឹងហើយ។

ក៖ ភាគច្រើនអត់ដាក់ឈ្មោះតែមួយ។

ខ៖ ឈ្មោះតែមួយ។

ក៖ ត្រកូលតែមួយ!!

ខ៖ចាំ!!

ក៖ អ៊ីចឹងអ្នកមីងសំរាប់ម្ដាយរបស់អ្នកមីងហាំ!!គាត់កើតនៅពេលណាមីងចាំអីគេអត់?

ខ៖ អត់ចាំផង ញ៉ុមអត់សួរចាំផង។

ក៖ ចាំ!!អ៊ីចឹងឥឡូវម្ដាយអ្នកមីងគាត់នៅរស់មែនទេ?

ខ៖ នៅរស់។

(កូន)៖ នៅរស់ឥឡូវទៅលក់កាលីងឈូកបាត់ហើយ។

ក៖ អ្នកលក់កាលីងឈូកហេ?

(កូន)៖ លក់នៅមុខរោងចក្រ។

ក៖ អ៊ីចឹងមីងកាលពេលមុនម្ដាយអ្នកមីងគាត់អ្នកលក់បន្លែហេ?

ខ៖ ចាំ!!

ក៖ ក្រៅពីលក់បន្លែហើយធ្វើស្រែគាត់មានធ្វើអីគេទៀតទេពីមុនមក?

ខ៖ ធ្វើតែស្រែហ្នឹង ធ្វើតែស្រែ។

(ស្វាមី)៖ នេះជំនាន់ហ្នឹងកាត់កំប្លោកធ្វើខ្សែលក់ហ្នឹងកាលជំនាន់ហ្នឹង។

ខ៖ ហ្នឹងហើយកាត់កំប្លោកលក់។

(ស្វាមី)៖ឈូសហាលធ្វើខ្សែដើរលក់ ។

ខ៖ ដើរលក់កាលហ្នឹងអត់ទាន់ប្រើស្បោងទេ។

ក៖ចាំ!!

ខ៖ កាត់កំប្លោកដើរលក់ ដើរលក់ផ្សារច្បារអំពៅយើងហ្នឹង ដើរលក់ហ្នឹងផ្សារច្បារអំពៅ ដល់ពេលគេលែង ដល់ពេលគេប្រើថង់ទៅ កាត់កំប្លោកហ្នឹងផ្អាកទៅ។

ក៖ចាំ!

ខ៖ផ្អាកទៅយើងប្រើស្បោងម្តង!!

ក៖ ចាំអ៊ីចឹងក៏ដាច់មុខរបររបស់គាត់ទៅ។

ខ៖ ចាំ!!

ក៖ គាត់ឆ្នាំអីគេឆ្នាំខ្មែរមីង?

ខ៖ ឆ្នាំខ្មែរឆ្នាំអីគេ!!

(ស្វាមី)៖ គ្រាន់តែគាត់ហ្នឹង៧៣។

ក៖ សព្វថ្ងៃហ្នឹងអាយុ៧៣ឆ្នាំហ្នឹង!!

ខ៖ឆ្នាំមមែដែរ។

កៈ មមែហោ?

ខៈ ចាំ!!មមែដែរ!!

កៈ មីងចាំគាត់កើតពេលណា អត់ចាំទេហោ?

ខៈ អត់ធ្លាប់ប្រាប់ផង។

(ស្វាមី)ៈ គ្រាន់តែគាត់និយាយសារបានជីវប្រវត្តិរបស់គាត់ហ្នឹងគឺគាត់កើតនៅពេទ្យរុស្សី។

កៈ គាត់កើតនៅពេទ្យរុស្សី!!!ចាំអីពីម៉ែខ្លះនិយាយប្រាប់អោយអស់មក មិនបាច់លាក់ទេ។

ខៈ អត់លាក់ទេ។

កៈ ដោយសារមួយហ្នឹងទុកអោយចៅៗឬក៏កូនៗមីងបានស្តាប់ពេលថ្ងៃក្រោយអីចឹងហាំ!!

ខៈ ចាំ!!

កៈ អ៊ីចឹងគាត់អ្នកស្រុកកំនើតមកពីណា?

ខៈ ចាំ?

កៈម៉ែហាំ?

(ស្វាមី)ៈ
ពីដើមគាត់មកកើតនៅពេទ្យរុស្សីមែនតែដល់ពេលរួចគាត់ក៏ទៅនៅស្រុកខាងបងប្អូនគាត់នៅឯខាងកំពង់កោរទាំងអស់។

ខៈ កំពង់កោរ។

កៈ អ៊ីចឹងនៅខាងកំពង់កោរហោ?

ខៈចាំ!!

កៈតែគ្រាន់តែកើតនៅពេទ្យភ្នំពេញទេតែទៅនៅកំពង់កោរ?

ខៈចាំ!!

(ស្វាមី)៖ បាទ!!

ក៖
មីងឥឡូវរៀបរាប់ពីម៉ែមើលម៉ែគាត់ជាមនុស្សម៉េចដែរ?មីងអាចរៀបរាប់អោយច្រើនមកក៏បាន
ដែរ!!

(ស្វាមី)៖ ហ៊ីម៉ែក្មេកញ៉ុមហ្នឹង
និយាយរួមទៅងាប់ដូចពស់រស់ដូចកង្កែបគាត់មិនដែលឈ្លោះជាមួយកណ្តុរក្រឡាតណាទេ!!

ក៖ និយាយមីងជាអ្នកនិយាយមើលលោរមីងដឹងច្រើនជាងពូ?

ខ៖ ញ៉ុមអត់សូវដឹងទេ!!

ក៖ ហ៊ីម៉ែខ្លួនឯងហាំម៉េចអត់សូវដឹងអីចឹង!!

(កូន)៖ ម៉ែគាត់អត់សូវនៅផ្ទះ!!

ក៖ ឥឡូវនិយាយពីពេលនៅក្មេង ពេលនៅក្មេងមីងម៉េចដែរពេលនៅរស់នៅជាមួយម្តាយាហាំ?

ខ៖ ពេលនៅក្មេងពេលរស់នៅជាមួយម្តាយបានតែនៅពេលនេះហ្នឹងពេលកើតហ្នឹង
ដល់ពេលនៅជំនាន់អាពតគេអោយបែកម៉ែហ្នឹង
បែកម៉ែហ្នឹងមិនដែលឃើញមុខម៉ែហ្នឹងម៉េចផងហ្នឹង ។

ក៖ ចុះពេលអាមុនជំនាន់សង្គ្រាមហ្នឹងវាម៉េចទៀត?

ខ៖ ជំនាន់សង្គ្រាមជំនាន់អាពត។

ក៖ មុនហាំមុនមុនហ្នឹងតើការរស់នៅជាមួយគាត់ហ្នឹងម៉េចដែរ?

ខ៖ កាលរស់នៅជាមួយគាត់គាត់មើលថៃយើងអញ្ចឹងទៅមើលថៃយើងធម្មតាអីចឹងទៅ
ដល់ពេលរួចទៅជំនាន់អាពតហ្នឹង ក៏បែកពីគាត់ទៅ
បែកពីគាត់ទៅមិនដែលឃើញមុខម៉ែហ្នឹងយ៉ាងម៉េចផងហ្នឹង!!

ក៖ហ៊ីៗ!!

ខ៖ បានទឹមមករ៉ៃបែកភ្នំពេញហ្នឹងបានឃើញមុខម៉ែហ្នឹង!!

ក៖ ចាំអញ្ចឹងពេលក្នុងជំនាន់ប៉ុល ពតហ្នឹងគេអត់អោយឃើញមុខម៉ែសោះម៉ងហោ?

ខ៖ អត់អោយឃើញមុខម៉ែទេ អត់អោយឃើញទេ ម៉ែគេអោយនៅដោយខ្លួនកូនគេអោយនៅដោយខ្លួនអ៊ីចឹងទៅណាស់អត់អោយឃើញទេ!!!! ដល់តែពេលស្រុកគេសាន្តត្រាណអ៊ីចឹងទៅណាស់បានឃើញមុខម៉ែ!!

ក៖ចាំ!!

ខ៖ ហ្នឹងហើយ។

ក៖ អ៊ីចឹងពេលហ្នឹងគាត់មានដើររកអ្នកមីងអីអត់ដល់ពេលស្រុកសាន្តត្រាណហើយ!!ស្រីមានតែមួយមែនទេ?

ខ៖ ហើយដើររក នៅពីអាពតគេអត់អោយដើររកទេ។ក៖ចាំ!!

(ស្វាមី)៖ អាហ្នឹងថាអញ្ចេកអាហ្នឹងនៅក្នុងអាពតអ៊ីចឹងទៅនៅក្នុងកងចល័តអី អ៊ីចឹងណាស់!!

ខ៖ ហ្នឹងហើយ ហ្នឹងហើយ គេអត់អោយរកទេ។

(ស្វាមី)៖ នៅក្នុងហ្នឹងអ៊ីចឹងទៅម្ដាយគេមិនអាចអោយរកកូនទេ កូនទៅរកម្ដាយ។

ក៖អ៊ីចឹងសុទ្ធតែលាក់គេអត់អោយម៉ង!! វាបើសិនជាទៅរកគ្នាវាសម្លាប់ចោលម៉ងមីងណោះ?

ខ៖ ហ្នឹងហើយ សម្លាប់ចោលម៉ង!!

ក៖ ហើយបើស៊ីបាយអញ្ចឹងដែរ បើថ្ងៃណាមានបុណ្យអញ្ចឹងណាស់ បានបាយមួយពេល បានបាយមួយពេល។

ក៖ មានបុណ្យទានជំនាន់ហ្នឹង?

ខ៖ មានតើ បុណ្យ!!

(ស្វាមី)៖ មានបុណ្យដូចថាបុណ្យរំលឹកអង្គការអីគេអញ្ចឹងទៅណាស់!!

ខ៖ ហើយដល់ពេលអញ្ចឹងទៅអរចង់ងាប់ហើយ។

ក៖ មួយៗសុទ្ធតែអរហើយមីងណោះ?

ខ៖ ហ្នឹងហើយ។

ក៖ចាំ!!

ខ៖ ដល់ពេលផុតពីហ្នឹងទៅបាយលាយត្រកួន បបរលាយត្រកួនក៏មាន។

ក៖ មើលតែជ្រូកហើយមីងណោះ?

ខ៖ ហ្នឹងហើយតែមួយកូនចានប៉ុណ្ណេះទេ ស៊ីបណ្តើរសុទ្ធអត់អោយយើងទឹកភ្នែកទេ សុទ្ធតែតាមដានមើល!! បើសិនជាយើងហូបបាយបណ្តើរយើងហូរទឹកភ្នែកបណ្តើរហាំ គេយកយើងវៃចោលហើយ។

ក៖ អ៊ីចឹងទៀត??

ខ៖ អាហ្នឹងជំនាន់អាពត។

ក៖ ហើយចុះមីងបន្ទាប់ពេលបែកប៉ុល ពត បន្ទាប់ពេលជួបម៉ែ ដំបូងមានអារម្មណ៍ម៉េចដែរ?

ខ៖ ជួបម៉ែដំបូងអរអ៊ីចឹងទៅបានជួបម៉ែយំសស្រែកសស្រាក់ដាក់គ្នាអ៊ីចឹងទៅ។

ក៖ ចាំតែពេលហ្នឹងមានបានដំណឹងថាគាត់នៅណានៅណីអត់?

ខ៖ នៅជិតគ្នាដែរប៉ុន្តែអត់អោយឃើញ នៅភូមិជាមួយគ្នាហ្នឹងហាំ!!

ក៖ចាំ!!

ខ៖ នៅភូមិជាមួយគ្នាប៉ុន្តែគេអត់អោយឃើញម៉ែទេ។

ក៖ ហ៊ឺៗ!!តែដឹងថាគាត់នៅរស់មីងណោះ?

ខ៖ចាំ ឃើញដែរតែអត់អោយហៅទេ!!

ក៖ បើហៅម៉េចទៅ?

ខ៖ អត់អោយហៅម៉ែទេ។

ក៖ បើហៅគេយកទៅសម្លាប់ចោលហោ?

ខ៖ ម៉ែក៏អត់អោយហៅកូន កូនក៏អត់អោយហៅម៉ែដែរ ដើរជួបគ្នាអញ្ចឹង!!

ក៖ ចាំ!!

ខ៖ តែអត់អោយហៅទេ។

ក៖ ហ៊ឺៗ!

ខ៖ ធ្វើដូចអ្នកក្រៅដទៃម៉ងហាំ!!

ក៖ចាំ!!

ខ៖ហ្នឹងហើយ។

ក៖ ចុះមីងដល់ពេលដូចជាជំនាន់ប៉ុល ពតហ្នឹងហើយមក
ដូចមីងរស់នៅជាមួយម៉ែរហូតមែនទេ?

ខ៖ ចាំ??បែកជំនាន់ប៉ុល ពតហើយអ៊ិចឹងហាំរស់នៅជាមួយម៉ែរហូតដល់សព្វថ្ងៃហ្នឹង។

ក៖ចាំ!!

ខ៖ហ្នឹងហើយ។

ក៖ អ៊ីចឹងគាត់ដូចអត់មានទៅណាដែរហោ?

ខ៖ អត់មានទៅណាទេ។

ក៖ ចុះឪពុករបស់អ្នកមីងហ្នំ!!

ខ៖ ឪពុកញ៉ុមស្លាប់។

ក៖ ហើយចុះបន្ទាប់ពីគាត់បែកពីជំនាន់ប៉ុល
ពតដោយសារពេលមុនយើងដឹងថាគាត់រកស៊ីលក់បន្លែ!!

ខ៖ កាត់កំប្លោក។

ក៖ កាត់កំប្លោកអីវ៉ាន់ ប៉ុន្តែបន្ទាប់ពីបែកពីប៉ុល ពតមក ម៉ែធ្វើអីគេវិញ?

ខ៖ ហ្នឹងកាត់កំប្លោកហ្នឹង៕

ក៖ កាត់កំប្លោកហ្នឹង!!

(ស្វាមី)៖ហើយធ្វើស្រែ!!

ក៖ ធ្វើស្រែហ្នឹង។

ខ៖ ធ្វើតែប៉ុណ្ណឹង។

ក៖ ដីធ្វើស្រែនៅឯណាវិញ?កំពង់កោរឬក៏នៅឯណាវិញ?

(ស្វាមី)៖ ចាក់អង្រែក្រោម។

ខ៖ នៅចាក់អង្រែក្រោមយើងនេះ!!

ក៖ ដីជួលគេឬក៏ម៉េច?

ខ៖ ដីរបស់ឯងហ្នឹង។

(ស្វាមី)៖ ដីគាត់ចាប់តាំងពី៧៩(១៩៧៩)។

ក៖ ចុះឥឡូវម៉េចឥលូវអត់បានដីហ្នឹងអីចឹង?

ខ៖ឈឺ។

ក៖ ឈឺក៏លក់ទៅមែន?

ខ៖ ហ្នឹងហើយលក់មើលខ្លួនហ្នឹងហាំ!! លក់មើលខ្លួន។

(ស្វាមី)៖ ស្មាទោស ប្រពន្ធញុំមឈឺដល់ថ្នាក់ឆ្កួតជ្រូកហ្នំ!!

ក៖ ហ្នំថីអីចឹងបានមីងចេះតែភ្លេចភ្លាំងច្រើនហោ?

ខ៖ចាំ!!

ក៖ ម៉េចដែរពេលហ្នឹងមីងពេលឈឺដល់ថ្នាក់ហ្នឹង មីងមូលហេតុអីគេ?

ខ៖ ចេះតែប្រកាច់។

ក៖ ហ្ហ៎!!

ខ៖ នេះថ្នាំញ៉ុមសាគួររាល់ថ្ងៃលេបរាល់ថ្ងៃហា!!

ក៖ហ៊ឺៗ!

ខ៖ ចេះតែប្រកាច់!!

ក៖ ប៉ុន្មានឆ្នាំហើយឈឺអាហ្នឹង?

ខ៖ ឈឺអាហ្នឹងហោ??ចាប់ផ្តើមតាំងពីញ៉ុមលក់ដីលក់អីហ្នឹងតាំងពីមុនមកម្ល៉េះ!!ឈឺរហូត ឈឺរហូត។

(ស្វាមី)៖ ផ្ទះនៅព្រែកហូរទីនេះលក់អស់មួយខ្នង។

ក៖ហ្ហ៎អ៊ីចឹងមីងនៅពេលមុននៅព្រែកហូរដែរហោ?

(ស្វាមី)៖ អត់ទេ!!

ខ៖ នៅចាក់អង្រែ។

(កូន)៖ គាត់លក់ផ្ទះពីចាក់អង្រែគាត់មកទិញនៅព្រែកហូរ!!

ក៖ មកទិញនៅព្រែកហូរ ហើយលក់ពីព្រែកហូរទៀត!!

(កូន)៖ ឥឡូវលក់ពីព្រែកហូរអស់ទៀត!!ជួលផ្ទះគេនៅម្តង!!

ក៖ អីយ៉ា!! អាហ្នឹងដោយសារឈឺបានលក់ហ្នឹងហោ?

ខ៖ ចាំឈឺ។

ក៖ ហើយទៅមើលនៅពេទ្យណាវិញ?

(ស្វាមី)៖ អូយពេទ្យច្រើនណាស់អ្នកគ្រូអើរ!!

ខ៖ មើលឡើងខ្យោះ ខ្យោះអស់!!

(កូន)៖ ពេទ្យគេលែងឡើងមើលគេអោយយកមកផ្ទះវិញគ្របក្រណាត់សរហើយហ្នឹង!!

ក៖ ហ៊ីតែម៉េចបានបានរស់ឡើងវិញ?

(កូន)៖ ឪហិចេះតែរកថ្នាំអោយគាត់ហូប។

ក៖ ថ្នាំខ្មែរអីមីង?

(កូន)៖ ថ្នាំខ្មែរថ្នាំអីទៅ គាត់ចេះតែកាប់ដាំហូបទៅ។

(ស្វាមី)៖ ថ្នាំខ្មែរខ្លះទៅថ្នាំពេទ្យខ្លះទៅ ព្រោះញ៉ុមពីដើមជំនាញពេទ្យដែរ។

ក៖ ចាំ ពូពេលមុនពេទ្យដែរហេ?

(ស្វាមី)៖ បាទ!!

ក៖ហ្ហ៎!!

(ស្វាមី)៖ រហូតដល់ពេទ្យដល់ចេះវះទៀតផង។

ក៖ តែពូម៉េចអត់ព្រមបន្តទៅ?

(ស្វាមី)៖ បាទ!!ញ៉ុមមិនអាចបន្តបានព្រោះញ៉ុមប្រលងជិតយកវេជ្ជបណ្ឌិតហើយហ្នឹង។

ក៖ហ្ហ៎!

(ស្វាមី)៖
នៅតែ៣ខែទៀតញ៉ុមប្រលងយកវេជ្ជបណ្ឌិតបានហើយប៉ុន្តែដោយសារខ្ញុំមានស្រីក្នុងសហគមន៍ហ្នឹង។

(កូន)៖ មានស្រីគេដេញចោល!!

(ស្វាមី)៖ អត់ទេ មានស្រីគេអត់ដេញទេ យើងដើរចេញម៉ង!!

ក៖ ហ្អ៎អឺចឹងទៀត!!

ខ៖ យើងកុំទៅអោយគេដេញឈប់ដើរចេញ។

ក៖អូខេឥឡូវកុំទាន់អាលសួរពូអី
សួរមីងសិនចាំបន្តិចទៀតដល់វគ្គពូម្តង!!ចាំជីកឬសជីកគល់ជីវិតរបស់ពូវិញ!!ឥឡូវមីងចាំអីគេទៀតពីម៉ែតើ កន្លែងមួយណាចំនុចមួយណាដែលអ្នកមីងស្រលាញ់ម៉ែជាងគេ?

ខ៖ ញ៉ុមស្រលាញ់ម៉ែ!!

ក៖ ដឹងតែស្រលាញ់ហើយតែចំនុចណា? ស្រលាញ់ត្រង់ណា?

ខ៖ ស្រលាញ់គាត់ធំម៉ង!! មិនដែលសំដីធំដាក់ម៉ែផងហ្នឹង មិនដែលសំដីធំដាក់ម៉ែអត់ទេ
អត់ដែលសំដីធំសំដីអាក្រក់ដាក់គាត់ទេ។

ក៖ហើយគាត់ក៏មិនដែលអីដាក់មីងដែរហី?

ខ៖ អត់!!

(កូន)៖ គាត់អត់ដែលជេរម៉ែឯងទេហី?

ខ៖  ម៉ែអត់ដែលជេរ។

ក៖ យាយជូហើយនឹងយាយផុសអ្នកណាគេកាចជាង?

(ស្វាមី)៖ យាយជូ!!

ខ៖ ពៅគេ!!

ក៖អឺចឹងយាយជូអត់សូវកាចដែរប៉ុន្មានណាហី?

ខ៖ អត់ទេ ។

(ស្វាមី)៖ យាយជូកាចគួរសម។

កៈ យាយផូឃើញ ញ្ញែញៗៗ!!

ខៈ ហើយបើម៉ែញ៉ុមអត់ទេ!!

កៈ ស្លូតវិញហោ!!

ខៈ ម៉ែញ៉ូមចង់កូនធ្វើម៉េចធ្វើទៅ!!គាត់អត់ចេះមាត់ទេ!!

កៈ អូខេឥឡូវចូលដល់នេះវិញម្ដង ដល់ប៉ាប៉ាវិញម្ដង ឪពុកមីង ឥឡូវឪពុកមីងគាត់ឈ្មោះអីគេដែរ?

ខៈ ឈ្មោះសង ។

កៈ អីគេសង?

(ស្វាមី)ៈ មិនមែនទេ យិន ទូចទេហី?? ម៉ែន ម៉ែន ទូច។

ខៈ ម៉ែន ទូច។

កៈ ម៉ែន ទូច?

ខៈ ចាំ!!

កៈ ឪពុកឈ្មោះម៉ែទូចមីងណោះ?

ខៈ ហ្នឹងហើយ។

កៈ ប្រាកដទេ?

ខៈ ប្រាកដ។

កៈ អូខេ អីចឹងមីងឥឡូវគាត់ស្លាប់បាត់ហើយណោះមីងនិយាយពេលមុន?

ខៈ ញ៉ុមនិយាយប្រវត្តិឪញ៉ុមម៉ែញ៉ុម ម៉ែញ៉ុមចុងគេ ម៉ែញ៉ុមប្រពន្ធចុងទេណាស់!!

កៈ ហ្ហ៎!!

ខ៖ញុំមនិយាយអោយអស់អញ្ចឹងម៉ង!!

ក៖ចាំ!!

ក៖ហ្នឹងហើយ!!អញ្ចឹងចុងទេអញ្ចឹងហោ?

ខ៖ចាំ!!

ក៖ ចុះឥឡូវឪពុករបស់អ្នកមីងឥឡូវមិនបាច់គិតចុងដើមអីទេឥឡូវសំខាន់គឺឪហើយ ឥឡូវគាត់មិញឈ្មោះយិនទូច ឬក៏ម៉ែនទូចមិញ?

(ស្វាមី)៖ ម៉ែន ទូច!

ក៖ ម៉ែន ទូច ឪពុកហោ?

ខ៖ចាំ!!

ក៖ គាត់ស្លាប់មូលហេតុអីគេដែរមីងដឹងទេ?

ខ៖ គាត់ជំងឺចាស់ ។

ក៖ហ្អ!!

ខ៖ ជំងឺចាស់ម៉ង!!

ក៖ ហាំគាត់ចាស់?

ខ៖ចាំ!!

ក៖គាត់ចាស់នៅក្នុងជំនាន់សង្គ្រាមហើយហ្នឹង?

ខ៖ ហ្នឹងហើយគាត់ចាស់ ជំនាន់សង្គ្រាមមកដល់ឥឡូវគាត់ចាស់ គាត់ជំងឺចាស់ ឈឺជំងឺចាស់ ។

ក៖ អ៊ីចឹងនៅក្នុងសង្គ្រាមហ្នឹងមីងគាត់ស្លាប់នៅក្នុងអាយុប៉ុន្មានវិញមីងដឹងអត់?

ខ៖ អត់ដឹងដែរ!!

(ស្វាមី)៖ គាត់មកស្លាប់យើង៨០(១៩៨០)ជាងហើយហ្នឹង។

ក៖ ហ្ហ៎អញ្ចឹងមិនមែនមកស្លាប់នៅក្នុងសង្គ្រាមហ្នឹងណាហី?

ខ៖ អត់ទេ។

(ស្វាមី)៖ អត់ទេ។

ក៖ ហ្ហ៎!! គាត់ស្លាប់ដោយសារមូលហេតុអីគាត់ឈឺហេ?

ខ៖ ចាំ!!ឈឺជំងឺចាស់ ថាជំងឺចាស់ហ្ហ៎!!

ក៖ចាំ!!

ខ៖ ហ្នឹងហើយ!!

ក៖អូខេអ៊ីចឹងចាំអីគេខ្លះពីឪ ឥឡូវនិយាយពីឪមើល!!ម៉េចដែរគាត់ហាំចាំ ចាំអីគេខ្លះពីគាត់?

(ស្វាមី)៖ ចាំប៉ុន្មាននិយាយប៉ុណ្ណឹងមក។

ខ៖ចាំតែប៉ុណ្ណឹង ចាំឪញ៉ុមគាត់ឈឺតែប៉ុណ្ណឹង ហើយអត់ចាំអីគេទៀតផង។

ក៖ ហើយចុះពេលនៅពីក្មេង គាត់មានដែលអីគាត់ដូចជាស្រលាញ់មីងខ្លាំងអីអត់?

ខ៖ នៅពីក្មេងស្រលាញ់ ហៅយើងកូនៗពេញមាត់ហ្នឹង ស្រលាញ់អត់ដែលវៃញ៉ុមទេឪញ៉ុមហ្ហ៎!

ក៖ អញ្ចឹងស្រលាញ់ដែរហេ?

ខ៖ ចា!!

ក៖ តែគាត់មានប្រពន្ធមុននេះទៀតហេ?

ខ៖មានមុនម៉ែញ៉ុម។

ក៖ មានមួយទៀត?

ខ៖ ចាំម៉ែញ៉ុមទី២។

កះចាំ!

ខះហើយម៉ែគាត់ដើមហ្នឹងឈ្មោះយាយមើយ។

កះ តែស្លាប់អស់រលីងហើយហោ?

ខះ ស្លាប់អស់ហើយ ស្លាប់អស់ហើយ!!

កះ ចាំ!!

ខះ ហ្នឹងហើយ។

(ស្វាមី)៖ ពីដំបូងតាមជីវប្រវត្តិហ្នឹងហាំញុំមស្តាប់ម៉ែក្មេកញុំមនិយាយញុំមស្តាប់បានទាំងអស់តាមពិតទៅគាត់ជាប្រពន្ធចុងមែនតែប្រពន្ធដើមមកដណ្តឹងគាត់រៀប។

កះ ហ្វូំ!!អញ្ចឹងសុទ្ធតែ មកពីប្រពន្ធដើមហ្នឹងមកដណ្តឹងអោយទេហោ?

ខះចាំ!!

កះ អ៊ីចឹងបានបានការអញ្ចឹងទៅ!!

ខះ ចាំ!!

កះហ្នឹងហើយ អ៊ីចឹងអ្នកមីងមីងសំរាប់ឪពុកអ្នកមីងគាត់អ្នកស្រុកមកពីណាវិញ?

ខះ ណា?

កះ ឪពុកហាំ?

ខះ ឪពុកញុំមហោ?

កះ នៅច្បារអំពៅហ្នឹងម៉ង។

កះហ្វូំ!!

ខះគាត់នៅច្បារអំពៅ!!!

ក៖អញ្ចឹងអើរឪពុកអ្នកកើតនៅភ្នំពេញទេ?

ខ៖ចាំ!!

ក៖ តែហើយតែម្ដាយមកពីកំពង់កោរឯណោះ?

ខ៖ ហ្នឹងហើយ។

ក៖ មីងស្រលាញ់ឪពុកខ្លាំងអត់?

ខ៖ ស្រលាញ់ស្មើគ្នា។

ក៖
កន្លែងចំនុចមួយណាដែលស្រលាញ់គាត់ខ្លាំងជាងគេដោយសារគាត់ស្លូតហើយមានអីគេផ្សេងទៀតទេ?

ខ៖ អត់មានទេ សុទ្ធតែស្រលាញ់ស្មើគ្នាតែម្ដង។

ក៖ ឪពុកអ្នកមីងគាត់រកស៊ីអីគេដែរដើម្បីចិញ្ចឹម?

ខ៖ ធ្វើសំនង់ ។

ក៖ មេសំនង់អីវ៉ាន់អ៊ីចឹងទៅ?

ខ៖ចាំ!!

ក៖អ៊ីចឹងវិញ។

ខ៖ ហើយម៉ែញ៉ុមក៏ធ្លាប់ធ្វើសំនង់ដែរ!!

ក៖ ធ្វើសំនង់ទៀត?

ខ៖ ចាំធ្វើសំនង់ទាំងអស់តែគ្នាហ្នឹង!!

ក៖ ពីមុនសង្គ្រាមពីមុនអាពតហ្នឹងធ្វើសំនង់ឬក៏បែកហើយ?

ខ៖ បែកហើយហ្នឹង។

ក៖ ចុះពេលអាមុនពេលធ្វើសង្គ្រាម៊

(ស្វាមី)៖ គាត់ធ្វើតាំងពីសង្គមហ្មំ!!

ខ៖ ពីសង្គម។

ក៖ សង្គមមកដែរអ៊ីចឹងហោ?

ខ៖ ចាំ!!

(ស្វាមី)៖ ព្រោះញុំមក៏ទាត់ឪក្មេកញុំមដែរ។

ក៖ ចាំអញ្ជឹងគាត់មានត្រូវនៅធ្វើស្រែចំការអីទៀតអត់ ឪ?

ខ៖ឪ!!

(ស្វាមី)៖ ឪអត់ដែលថាឃើញធ្វើអីផងទេ!!

ក៖ អត់ទេអញ្ជឹងហោ?

(ស្វាមី)៖ ឃើញតែធ្វើតែសំនង់។

ក៖ ហ្មំអ៊ីចឹងសំរាប់ធ្វើតែជាងសំនង់ហ្នឹងតែមួយមុខគត់ទេហោ?

ខ៖ ជាងហ្នឹង។

ក៖ ហ្នឹងហើយ។ចាំអញ្ជឹងមីងចូលដល់នេះវិញម្ដង !!មានអីចង់រៀបរាប់ពីឪអីទៀតទេ?

ខ៖ អត់ដឹង ញុំមកើតមកញុំមឃើញតែត្រឹមហ្នឹង។

ក៖ ចាំអញ្ជឹងដឹងតែត្រឹមហ្នឹងទេចុះ?

ខ៖ ប្រវត្តិឪញុំមដឹងតែធ្វើម៉េច ម៉ែញុំមដឹងតែថាឪញុំមធ្វើសំនង់។

ក៖
អ៊ីចឹងអ្នកមីងពេលមុនសង្គ្រាមហ្នឹងពេលរស់នៅជាមួយឪពុកម្ដាយសប្បាយមានសុភមង្គលច្រើនទេ?

ខ៖ អត់មានបាននៅទេ។

ក៖ មុនសង្គ្រាមហាំ ពេលមុនអត់ទាន់មានសង្គ្រាមហ្នំមានសប្បាយ?

(ស្វាមី)៖ នៅតែជាមួយគ្នាហ្នឹង។

ខ៖ នៅជាមួយគ្នាហ្នឹង។

ក៖ រស់នៅធម្មតាអីអ៊ីចឹងដែរទៅ?

ខ៖ចាំ!!ហ្នឹងហើយ។

ក៖ចាំឥលូវចូលដល់យាយឥឡូវនិយាយខាងម៉ែហាំ!!

ខ៖ចាំ!!

ក៖ យាយរបស់មីងគាត់ឈ្មោះអីគេ?ខាងម៉ែ?

ខ៖ យាយម៉ែញុំមហេ?

ក៖ មិនមែនយាយរបស់មីងទេ យាយរបស់ម៉ែមីង ខាងម៉ែ?

ខ៖ កើតអត់ទាន់ទេ អត់ទាន់យាយផងហ្នឹង។

ក៖ ហើយដែលមានម៉ែប្រាប់ថាយាយឈ្មោះអីគេអត់?

ខ៖ អត់អត់និយាយផង។

ក៖ ម៉េចអ៊ីចឹងវិញ?

ខ៖ ដឹងអី កើតមកឃើញតែមុខម៉ែ អត់ឃើញមុខយាយមុខមិនដឹងម៉េចផង អត់ឃើញផង។

ក៖ តែម៉ែក៏អត់ឃើញនិយាយអីពីយាយដែរហេ?

ខ៖ អត់ អត់។

ក៖ ហើយម៉េចអញ្ជឹង??

ខ៖ បើកើតមកឃើញតែមុខម៉ែហ្នឹង។

ក៖ ចាំហ្នឹងហើយ។

ខ៖កើតអត់ទាន់យាយផងហ្នឹង។

ក៖ ហ៎!!អ៊ីចឹងពិបាកដែរ ហើយដឹងថាយាយមកពីណាពីណអ្នកស្រុកណាអីអត់?

ខ៖ អត់ដឹងផង។

ក៖អត់ទាំងអស់ម៉ង?

ខ៖ ហ្នឹងហើយ។

ក៖ ឥឡូវចុះតាវិញ?

ខ៖ តាក៏អត់ដែរ។

ក៖ អត់ដូចតែយាយដែរ?

ខ៖ ដូចគ្នា។

ក៖ ចាំ!!តែត្រកូលរបស់ម៉ែមីញឈ្មោះអីគេត្រកូល៍

ខ៖ ត្រកូល ម៉ែន ផុស។

ក៖ អ៊ីចឹងប្រហែលឈ្មោះតាម៉ែនហើយណោះ?

ខ៖ ហ្នឹងហើយ។

(ស្វាមី)៖ ដឹងមែនហ៎ក៏មិនមែន!!ប្រហែលជាមុនយាយតាហ្នឹងទៀត!!

ក៖ អត់ច្បាស់មីងពូ!!អ៊ីចឹងអត់ដែលបានស្គាល់អី
អត់ដែលបានឃើញមុខតាយាយខាងម៉ែហ្នឹងម៉ង!!

ខ៖ ចាំ!!

កះ គួរតែនៅជាមួយយាយរហូតគួរតែដឹង!!

ខះអត់ដឹង។

កះគួរតែម៉ែបានប្រាប់ខ្លះអ៊ីចឹងទៅណាស់ពីយាយអ៊ិចឹងទៅ!!អញ្ចឹងមីងចូលដល់ជីដូនជីតាខាងឪពុកវិញធ្លាប់ស្គាល់ពួកគាត់តអត់?

ខះ អត់ស្គាល់។

កះ ទាំង២សងខាងហ្នឹងគឺអត់ស្គាល់ទាំងអស់ម៉ង?

ខះ អត់ស្គាល់ទាំងអស់។

កះ
តែគ្រាន់តែដឹងថាឪមកពីច្បារអំពៅហ្នឹងប្រហែលជាដូនតាអ្នកមីងខាងឪពុកមកពីច្បារអំពៅដែរហើយមីងណោះ?

ខះ ហ្នឹងហើយ ។

កះ
អញ្ចឹងអ្នកមីងសំរាប់ជីវិតអ្នកមីងពេលវេលាណាដែលអ្នកមីងពិបាកជាងគេនៅក្នុងជីវិតទៅ?

ខះ ពិបាកជាងគេក្នុងជីវិតហ្នឹងហោ?

កះហ៊ីៗ!!

ខះ ជំនាន់អាពតហើយនឹងឥឡូវហ្នឹងក៏នៅតែពិបាកដែរ និយាយអោយចំទៅ
ជំនាន់ឥឡូវហ្នឹងជំនាន់ឥឡូវហ្នឹងក៏នៅតែពិបាកដែរ។

កះ ហើយម៉េចបានពិបាកបើពេលមុនគេរកតែសម្លាប់ហើយឥឡូវអ្នកណាគេសម្លាប់មីងផង?

(ស្វាមី)៖ វាពិបាកលើជីវភាព។

ខះ ពិបាកត្រង់ជីវភាព
ជំនាន់អាពតពិបាកខ្លាចគេសម្លាប់!!ដល់ឥឡូវវាពិបាករឿងជីវភាពយើងរស់នៅម៉ងទៅណាស់!!

កៈចាំ!!

ខៈ ហ្នឹងហើយ។

កៈតឹងណាស់អីចឹង?

ខៈហ្នឹងហើយ។

កៈអីចឹងតាមពិតជីវភាពរបស់អ្នកមីងពិបាកដោយសារតែអ្នកមីងនេះតើហី?អ្នកមីងឈឺហោ?

ខៈ ឈឺ!!

កៈ ដល់ពេលឈឺលក់ដីលក់ផ្ទះអស់រលីងទៅបានអញ្ចឹងទៅ?

ខៈ ចាំ!!

(ស្វាមី)៖ រសោត់សែងត្រែងមកដល់នេះ!!

កៈហុីៗ!!

ខៈ បើកុំឈឺអត់អីទេមីងណោះ?អត់អីទេ រាល់ថ្ងៃលេបតែថ្នាំរាល់តែថ្ងៃហ្នឹង អត់លេបថ្នាំប្រកាច់ អត់លេបថ្នាំប្រកាច់។

កៈ ប៉ុន្មានថ្ងៃលេបថ្នាំម្តង?

ខៈ រាល់ថ្ងៃលេបព្យាយាមរាល់ថ្ងៃតែម្តង។

(ស្វាមី)៖ មួយថ្ងៃ២ដង។

កៈហើយពេទ្យ មកពីពេទ្យណាវិញទៅយកថ្នាំពេទ្យអីហ្នូ??

ខៈ ទៅទីញ។

(ស្វាមី)៖ ទីញមួយប្រអប់ហ្នឹងវា៦ដុល្លារ។

កៈ ហ្នុំទិញពីហ្វាម៉ាសុីមក មិនមែនបើកពីរុស្សីអីណាហី?

ខ៖ អត់ទេ។

(ស្វាមី)៖ អត់ទេទិញពីហ្វាម៉ាស៊ីហើយថ្នាំហ្នឹងក្នុង១០០គ្រាប់ហ្នឹង២នាក់ លេប២នាក់ កូនខ្ញុំមួយពិការហ្នឹង នេះអានេះទឹមតែប្រកាច់ហើយ។

ក៖ហើយម៉េចអ៊ីចឹងបានពិការពូ?

(ស្វាមី) ៖ វាពីដើមមកវាកើតមកវាល្អជាណាស់។

ក៖ចាំ!!

(ស្វាមី)៖ប៉ុន្តែដល់ថ្នាក់វាឈឺដល់ថ្នាក់យកទៅពេទ្យគន្ធបុប្ផា ហើយដល់អ៊ីចឹងទៅមិនដឹងជាមូលហេតុអី បានវាទៅជាងាប់មួយចំហៀងខ្លួននេះ។

ក៖ ឥឡូវស្លាប់មួយចំហៀងខ្លួនហេ?

ខ៖ បាន មើលក្រវៃក្រវង់អស់ហើយនឹង។

ក៖ ពិបាកណាស់អ៊ីចឹងដល់ពេលកូនឈឺ មីងឈឺ ពូឈឺទៀត ហ៊ីមួយក្រុមគ្រួសារនេះអត់មានលើកលែងអោយអ្នកណាគេមួយហើយហេ??

ក៖ ពិបាកណាស់មីងដល់ពេលអញ្ចឹង??

ខ៖ចាំ!!

ក៖ហើយដល់ពេលអញ្ចឹងរាល់ថ្ងៃមីងរកស៊ីអីគេដែរ?

ខ៖ នោះរើសអេតចាយ កូនដើរសុំទានគេហ្នឹងមកទិញថ្នាំប្រកាច់អោយម្ដាយលេបផងអោយខ្លួនឯងលេបផងហ្នឹងហាំ!! ឥឡូវថ្នាំជិតអស់ហើយនៅសល់១គ្រាប់ហ្នឹង បើសិនជាញ៉ុមលេបទៅអត់វា លេបវាអត់ញ៉ុម ។

ក៖ចាំ!!

ខ៖ ដល់ពេលរកបានតែ៤០០០ ៥០០០អ៊ីចឹងទៅយកលុយទិញថ្នាំលេបខ្លះទៅទិញម្ហូបខ្លះទៅ អង្ករខ្លះទៅ។

ក៖ ចុះយាយអីវ៉ាន់អត់ជួយណាហី យាយជាមួយដែរ?

ខ៖ ម៉ែជួយដែរ។

(ស្វាមី)៖ ម៉ែជួយ គាត់ជួយដែរ។

ខ៖ គាត់ជួយដែរ។

ក៖ ហើយអ៊ីចឹងពិបាកណាស់អ្នកមីង
អ៊ីចឹងអរគុណច្រើនអ្នកមីងសំរាប់ការសំភាសន៍ដែលអ្នកមីងបានប្រាប់អំពីជីវប្រវត្តិរបស់ខ្លួនឯងក៏ដូចជាជូនតាហើយអ្វីទាំងអស់កូនចៅអ្នកមីងគាត់នឹងបានស្តាប់ឮនូវសំដីក៏ដូចជាពាក្យពេចន៍ទាំងឡាយដែលអ្នកមីងបានអ្នកមីងរៀបរាប់ពីប្រវត្តិជូនតាអ្នកមីង!!

ខ៖ ចាំ។